និពន្ធចងក្រង ដោយលោកគ្រូអាចារ្យ ឃុត ឃឹម Tel: 012-633-218 អាចារ្យការ & មើលវេលាការ
នៅភូមិស្នោរ ឃុំស្នោរ ស្រុកអង្គស្នួល ខេត្តកណ្តាល

# ក្បួនច្បាប់ចៅមហាក្លួងពិធី

# រៀបអាពាហ៍ពិពាហ៍

## ក្បួនច្បាប់ចៅមហាក្លួងពិធីរៀបអាពាហ៍ពិពាហ៍

## ឬ(ក្លួងកិច្ចនម្រង់ការ)

ដែលនិពន្ធរៀបរៀងចងក្រងដោយលោកគ្រូអាចារ្យ ឃុត ឃឹម
នៅភូមិស្នោរ ឃុំស្នោរ ស្រុកអង្គស្នួល ខេត្តកណ្តាល
(លោកគ្រូអាចារ្យ ឃុត ឃឹម Tel: 012-633-218 អាចារ្យការ & មើលវេលាការ )



ជំនួយការចងក្រង និងផ្សព្វផ្សាយដោយលោក គោគ សំអុន មន្ត្រីនាយកដ្ឋាន
សិល្បៈទស្សនីយភាព នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។
កែសំរួល ដោយលោតា មៀច_ប៉ុណ្ណ ក្រុមជំនុំធំនៀមទម្លាប់ ពុទ្ធសាសនបណ្ឌិត្យ
Tel: 012 – 943 - 138

សហការដោយ

AngkorDaily.com AngkorPost.com
Sales@AngkorLink.com

រក្សាសិទ្ធិគ្រប់យ៉ាង

## ពិធីទម្រង់ការអាពាហ៍ពិពាហ៍(តាមទំនៀមបុរាណខ្មែរ)

### ពិធីហោងរោង ( ហោមពិធី ) បទហោងរោង

-សែនគ្រូពាលី

### ផ្តើម : បទហោងរោង

**-ចៅមហា :** (និយាយពីបទហោងរោង) សូមគោរពអញ្ជើញភ្ញៀវកិត្តិយសទាំងខាងប្រុស ទាំងខាងស្រី អញ្ជើញជួយ កាន់គ្រឿងបណ្ណាការ ចេកទុំនំផ្អែម កំណត់ពេលារាសី ។

-ឥឡូវឃើញថា ភ្ញៀវកិត្តិយសបានមកជួបជុំគ្នាអស់ហើយ បន្ទាប់មកសូមលោកអ្នកភ្លេងលេងបទ ចៅព្រាហ្ម ដើម្បីហែហាមគ្រឿងបណ្តាការទៅកាន់គេហដ្ឋានខាងស្រី ហ៎ "សូមសំឡេងឃ្មោះបន្លឺឡើង"

**-បទ ចៅព្រាហ្ម** (លេងមួយចប់)

**-ចៅមហា :** (និយាយ) សូមឱ្យអ្នកផ្លូវខាងស្រីទាំងបីនាក់ និយាយស្តីដណ្តឹងចែចូវកូនស្រីលោកមេបា

**-អ្នកផ្លូវ :** (និយាយ) ត្បិតលោកភោគផល្លាមហាសម្បត្តិ បានពឹងព រកនាងខ្ញុំទាំងបីនាក់ ឱ្យធ្វើជាអ្នកស្នេរ ចែចូវ អ្នកផ្លូវ ស្រីទាំងបីនាក់ មកស្តីដណ្តឹងកូនស្រីលោកមេបា ។

ឥឡូវនាងខ្ញុំសូមក្រាបប្រណិប័តន៍អស់លោកមេបាចម្បងរងបន្ទុក ឪពុកម្តាយ ។

**-មេបា :** សូមលើកដៃថ្វាយព្រះ

**-អ្នកផ្លូវស្រី :** សូមទានជ្រាបជំរាបអស់លោកមេបា ឧកញ៉ា ព្រះភ្វា ត្រកូលរៀមច្បង ប្រុស-ស្រី តូចធំ ទាំងប៉ុន្មាន សូម ទានជ្រាប ត្បិតពីថ្ងៃមុនលោកភោគផលាមហាសម្បត្តិ បានពឹងព រកនាងខ្ញុំឱ្យធ្វើជាអ្នកស្នេរ ចែចូវ អ្នកផ្លូវស្រីទាំងបីនាក់ ចូលមក ស្តីដណ្តឹងកូនស្រីលោកមេបា នាងខ្ញុំហៅពីចំងាយដូចជាមិនគួរគប្បី ហៅពីដីដូចជាមិនសម នាងខ្ញុំសូមលើកដៃប្រណម្យ គាល់ លោកមេបា សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា :** (ឆ្លើយ) ខ្ញុំរកតែអ្នកស្រឡាញ់ទេ បើស្រឡាញ់ឱ្យមកញឹក បើរលឹកឱ្យមកញយ អ្នកមុនកម្សោយ (ខ្សោយ) អ្នកក្រោយ មានលាភ ។ សូមឱ្យអ្នកផ្លូវមានប្រសាសន៍បន្តទៀត ។

**-អ្នកផ្លូវ :** សូមទានជ្រាបជំរាបអស់លោកមេបា កាលគ្រាវេលាមុននាងខ្ញុំសុំអុជទៀនទាំងគូឆ្វេងស្តាំ សុំនិយាយការ លោក មេបាស្រីក៏ព្រមអនុញ្ញាតដល់ឃ្លានេះទៀត នាងខ្ញុំសុំដើរផ្លូវ ជណ្តើរឡើង សុំកន្ទេលទ្រនាប ទ្រាប់ដាក់ប្រដាប់ប្រដា ម្លូស្លា ចេក ទុំនំផ្អែម ។

**-មេបា :**

**-អ្នកផ្លូវ :** សូមទានជ្រាបជំរាបលោកមេបា កាលគ្រាវេលាមុន លោកមេបាឱ្យនាងខ្ញុំស្រឡាញ់ហើយ ឃ្លានេះទៀតនាងខ្ញុំសុំស្រឡាញ់ដល់កូនស្រីលោកមេបា តើកូនស្រីលោកមេបាមានទាក់ទិនទៅអ្នកឯណាហើយឬក៏នៅឡើយ សុំប្រសាសន៍ សូមទានជ្រាប ។

**-មេបា :** (ស្រី) កូននាងខ្ញុំឥតទាន់មានទាក់ទិននឹងគេទេ(សូមទានជ្រាប)

**-អ្នកផ្លូវ :** សូមទានជ្រាបជំរាបអស់លោកមេបា កាលគ្រាវេលាមុនលោកមេបាមានប្រសាសន៍ថា កូនស្រីលោកឥតមានទាក់ ទិននឹងគេទេ ឃ្លានេះទៀតនាងខ្ញុំសូមក្រាបប្រណិប័តន៍ សុំស្ដីដណ្ដឹងកូនលោកមេបាឈ្មោះនាង(............)ជាកូនស្រីលោក មហាសេដ្ឋី ឱ្យទៅបណ្ដិត (..........) កូនលោកភោគផលាមហាសម្បត្តិ សូមជាសាច់ជាសន្ដានជាស្ពានមេត្រី សុំស្ដីដណ្ដឹងជាគូ ស្រករតរៀងទៅ សូមប្រសាសន៍សូមទានជ្រាប ។ ។

**-មេបា :** មើលកូនប្រុសអ្នកផ្លូវស្រីមានចេះអ្វីខ្លះ តើចេះកាច់សង្រែកចងរែក ធ្វើជាលភ្អែកក្រួចដែរឬទេ?

**-អ្នកផ្លូវ :** សូមទានជ្រាបជំរាបអស់លោកមេបា លោកសួរនាងខ្ញុំថា តើកូនប្រុសខាងនាងខ្ញុំនេះណា ចេះធ្វើកិច្ចការទាំងបីនេះទេ កិច្ចការទាំងបីនេះកូននាងខ្ញុំចាំសព្វគ្រប់អស់ហើយ សូមទានជ្រាប ។

**-មេបា :** ហើយតើកាច់សង្រែក , ចងរែក និងធ្វើជាលភ្អែកក្រួចនេះ មានន័យយ៉ាងម៉េច សូមអ្នកផ្លូវឆ្លើយ ។

**-អ្នកផ្លូវ :** សូមទានជ្រាប ជំរាបអស់លោកមេបា ពាក្យកាច់សង្រែកមានន័យថា ចេះរែក ឬថ្លឹងឱ្យស្មើគ្នា រវាងក្រុម គ្រួសារទាំងសងខាង ។ ពាក្យថាចងរែក មានន័យថា ឱ្យដឹងត្រជាក់ក្ដៅ ន័យត្រង់ហ្នឹងបើរកទទួលទានត្រជាក់ក្ដៅយ៉ាងណា ឬ ជួបហេតុការណ៍យ៉ាងណា ត្រូវចេះអត់ធ្មត់ ហើយពាក្យថា ចេះធ្វើជាលភ្អែកក្រួច មានន័យថា ទោះស្ថិតក្នុងកាលៈទេសៈណា ក៏ដោយ ត្រូវចេះរាប់ញាតិ កុំឆ្មើងឆ្មៃនឹងមាតាបិតា ញាតិសន្ដានទាំងសងខាង ។

**-មេបា :** ការបកស្រាយរបស់ អ្នកផ្លូវនេះពិតជាត្រឹមត្រូវហើយ ដូច្នេះការចងស្ពានមានមេត្រីស្ដីដណ្ដឹងកូនស្រីខ្ញុំនេះ យើងខ្ញុំពុំយល់ទាស់ទេ ។ ប៉ុន្តែកូនស្រីនាងខ្ញុំនេះមានមេមានបា សូមបង្វែរបង្កិលបង្វិលអង្គុយទៅរកលោកមេបាប្រុសចុះ ។

**-អ្នកផ្លូវ :** សូមទានជ្រាបជំរាបអស់លោកមេបា កាលគ្រាមុននាងខ្ញុំមកមួយគ្រាជាពីរគ្រា ឥឡូវគំរប់ជាបីគ្រា លោក មេបាមានប្រសាសន៍ថា ខ្លួនលោកជាស្រី នាងខ្ញុំក៏ជាស្រី សំដីទន់ប្រពន្ធគេផង លោកមេបាស្រីបានឱ្យនាងខ្ញុំបង្វែរបង្កិលបង្វិល ទៅរកលោកមេបាប្រុស ដូច្នេះនាងខ្ញុំសូមក្រាបប្រណិប័តន៍លា ។

**-អ្នកផ្លូវ :** សូមក្រាបប្រណិប័តន៍លោកមេបា

**-មេបា :** លើកដៃថ្វាយព្រះ សូមអ្នកផ្លូវមានប្រសាសន៍

**-អកផ្លូវ** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុននាងខ្ញុំសុំស្ដីដណ្ដឹងកូនស្រីលោកមេបាស្រី លោកក៏មាន ប្រសាសន៏ថា ខ្លួនលោកជាស្រី នាងខ្ញុំក៏ជាស្រីសំដីមិនអស់មិនហើយ ដូច្នេះនាងខ្ញុំសុំស្ដីដណ្ដឹងកូនស្រីលោកមេបាឈ្មោះ ........... សូមទានជ្រាប ។

**-មេបាប្រុស** : ការដែលនាងមកស្ដីដណ្ដឹងដល់មេបាស្រី នោះលោកមេបាស្រីបានយល់ព្រមហើយ ឯយើងជាមេបាប្រុសក៏មិនយល់ទាស់អ្វីដែរ ពីព្រោះមេបាប្រុសនេះទុកដូចជាជើងក្រោយ តែងតែដើរតាមជើងមុខជាដរាប ។ ប៉ុន្តែលោកមេបាសុំសួរទៅអ្នកផ្លូវស្រីទាំងបី តើនាងអ្នកផ្លូវអាចទទួលរ៉ាប់រងមង្គលការក្នុងយប់មួយថ្ងៃពីរបាន ឬពុំបាន ? សូមអ្នកផ្លូវមានប្រសាសន៏ ។

**-អ្នកផ្លូវ** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនលោកមេ បានបានបង្គាប់ឱ្យនាងខ្ញុំទទួលរ៉ាប់រងកិច្ចទម្រង់ការ ជូនលោកមេបា សូមជំរាបប្រសាសន៏ ក្នុងកិច្ចទម្រង់ការនេះ នាងខ្ញុំទទួលពុំបានទេ ពីព្រោះនាងខ្ញុំជាស្រីសំដីតិចភ្លេចក៏ច្រើន នាងខ្ញុំសូមបង្វែរបង្អិលបង្វិលចុះតាមកាំជណ្ដើរ ដើរទៅរោងជ័យទៅប្រាប់អ្នកសាមិដើមពុំនឹង ឱ្យទៅពិតរកអ្នកមុខអ្នកការ អ្នកដែលចេះនិយាយទម្រង់ការចំនួនបីនាក់ សូមឱ្យលោកមេបាពិតពិលរមិលមើលរូបឆោមលោមពណ៌អ្នកទាំងបីនេះ សូម ប្រសាសន៏សូមទានជ្រាប ។

**-ចៅមហា** : សូមក្រាបប្រណិប័តន៏អស់លោកមេបា ចម្បងរងបន្ទុកឪពុកម្ដាយ ភ្ជាក់ដៃលើភ្ជាក់ដៃក្រោម សូមលោក ពិតពិលរមិលមើលរូបឆោមខ្ញុំបាទ ។

**-មេបា** : រូបឆោមលោមពណ៌កម្ពស់កំព នោះត្រឹមត្រូវហើយ ប៉ុន្តែបើអ្នកមានកើត គ ថ្លង់ ប្លូស បម កម រមាស់ ស្រែងស្រកី អណ្ដែង ជជុះមាន់ ដែរឬទេ?

**-ចៅមហា** : (ឆ្លើយ) ខ្ញុំបាទឥតមានកើត គ ថ្លង់ ប្លូស បម កមរមាស់ ស្រែងស្រកី អណ្ដែង ជជុះមាន់ ទេ ។

**-មេបា** : បើដូច្នេះសូមលោកបញ្ចេញឈ្មោះពិគ្រោះសំដី លោកមេបាប្រុស ស្រីមកមើល៎

**-ចៅមហា** : ខ្ញុំបាទមុននឹងបញ្ចេញឈ្មោះពិគ្រោះយោបល់ លោកមេបាប្រុស-ស្រី ខ្ញុំបាទសុំខន្តីអភ័យទោសក្រែងខ្ញុំ បាទនិយាយទៅហើយខ្លីពេក សូមឱ្យលោកមេបាជួយបំពេញ បើខ្ញុំបាទនិយាយលើសទៅវិញ សុំឱ្យលោកមេបាបន្ថយ សូមប្រ សាសន៏ សូមទានជ្រាប ។

+(ចៅមហានិយាយតាមឃ្លា) សូមទានជ្រាបខ្ញុំបាទ បានរៀបប្រដាប់រងដាំក្លាំថ្លល់តម្កល់ទឹកថ្លា ស្លាថង់ផ្លូវវិចិត្រ ចូលមក គោរពប្រណិប័តន៏អស់លោកមេបា ត្រកូលរៀមច្បងផងទាំងឡាយជិតឆ្ងាយទាំងប៉ុន្មាន សូមទានជ្រាប ។

ត្បិតពីថ្ងៃមុន អ្នក(ក) អ្នក(ខ) គាត់មានសេចក្ដីស្រឡាញ់រាប់រកតែអ្នក (គ) អ្នក (ឃ) ហើយឧស្សាហ៍ទៅមកប្រា ស្រ័យទាក់ទង ហេតុតែភូមិផងរបងជាមួយ ។(ហេតុតែភូមិគាត់នៅឆ្ងាយពីគ្នាក៏ដោយ) ស្រាប់តែពេលមួយនោះគាត់ក៏បាន ឃើញកូនក្រមុំរបស់អ្នក (គ) អ្នក (ឃ) មានរូប ឬកពារ សមរម្យ

សល្អស្អាតជាឧត្តមសមនឹងដងខ្លួន ធួននឹងកម្ពស់ សម្ដី ពិរោះ ស្រស់ទាំងសម្បុរ ក្រឡេកមើលយល់ក៏មានសេចក្ដីស្ម័គ្រជំពាក់ក្នុងអង្គប្រាណគិតចង់បាន ឱ្យទៅអន្ទិត(............)ជាកូន របស់គាត់ ម្យ៉ាងទៀតក៏បានស៊ើបសួរ អ្នកស្រុកភូមិផងរបងជាមួយ បានដឹងខែ ឆ្នាំចាំជាក់រួចស្រេចកាលណា គាត់ក៏អញ្ជើញ ទៅផ្ទះលោកអាចារ្យ ឱ្យលោកគន់គូរលេខក្នុងសម្ពង្ស សម្អាភ្លឹកឬកដួងជតា បើតាមលេខលោកអាចារ្យ លោកថាកូនចៅទាំងពីរ នាក់ដែលមាតាបិតារៀបចំទុកដាក់ឱ្យជាគូស្រករ ស្វាមីភរិយា ក្នុងថ្ងៃនេះមានសិរីសួស្តី ស័ក្ដិសមនឹងគ្នាណាស់ គាត់ក៏មានបីតិ សោមនស្សស្រស់ស្រាយ សប្បាយក្នុងសន្ដានចិត្តឥតឧបមា ក៏ក្រាបប្រណិប័តន៍លាលោកអាចារ្យធ្វើវន្ទនកិច្ចស្រូតរូតដល់ផ្ទះ កាលណា ក៏រៀបចំស្លាម្លូ មិនយូរគាត់ក៏ទៅពឹង អ្នកផ្លូវស្រីទាំងបីនាក់ ឱ្យមកស្ដីដណ្ដឹងកូនលោកមេបា មក១ឃ្លាជា២ឃ្លា គំរប់ជា ៣ឃ្លា លោកមេបាក៏មានប្រសាសន៍ថា អ្នកផ្លូវស្រីនិយាយសំដីជាឧត្តម សមគួរជាសួស្ដីហើយ តែខ្លួននាងជាស្រីសំដីទន់ ប្រពន្ធ គេផង លោកមេបាសំរេចការពុំទាន់បាន លោកមានប្រសាសន៍ឱ្យអ្នកផ្លូវស្រីទាំងបីបង្វែបង្កិលបង្វិល ចុះតាមកាំជណ្ដើរ ដើរដល់រោងជ័យ ទៅប្រាប់អ្នកសាមិត្រីពុំនឹងឱ្យទៅពឹងពរក៏អ្នកដែលមានតម្រិះ អ្នកដែលចេះនិយាយទម្រង់ការ អ្នកសាមិត្រី ពុំនឹងក៏បានទៅរើងទៅពឹងព រកខ្ញុំបាទទាំងបីនាក់ ឯខ្ញុំបាទឈ្មោះ កែវ ប្រពន្ធឈ្មោះ កង អ្នកដែលកាន់ថង់រងឈ្មោះ សុខ ប្រពន្ធ ឈ្មោះ សីរី អ្នកនៅក្បែរមាត់ជណ្ដើរកាន់ក្បាក់ចាក់ទឹកថ្លាជូនលោកមេបា ឈ្មោះ សម នៅ លីវ នៅ (ភូមិ ............ឃុំ........ ស្រុក............ខេត្ត............) ។

សូមឱ្យលោកពិតពិលរមិលមើលរូបឆោមលោមពណ៌ខ្ញុំទាទទាំងបីនាក់ បើលោកពិតពិលរមិលមើលទៅហើយ ល្មមនឹង ទុកដាក់ឱ្យខ្ញុំបាទនិយាយក្នុងទម្រង់ការជូនលោកមេបាបាន ឬពុំបាន សូមប្រសាសន៍ សូមទានជ្រាប ។

**- មេបា** : សំដីថ្វីមាត់នេះឃើញថា ពិរោះពិសាហើយ ល្មមសមរម្យអាចបំរើកិច្ចការជូនមលោកមេបាបាន ។

**- ចៅមហា** : សូមទានជ្រាបជំរាប លោកមេបា

កាលឃ្លាមុនខ្ញុំបាទបានជូនខ្លួនទាំងបីនាក់ឱ្យលោកពិតពិលរមិលមើល រួចសព្វគ្រប់ គ្រានេះខ្ញុំបាទគោរពសុំអនុញ្ញាតពាក់អាវចិនតាង តំណាងអាវផាយរំសាយមាត់ថង់ តំរង់កូនប្រអប់ ផ្ទាប់ដាក់ចាក់ ស្រាដាក់ពែងស័រិទ្ធ សូមអុជទៀនទាំងគូបិទមាត់ក្បាក់ មាត់ថង់រង សូមមានប្រសាសន៍តាមទំនុកទំនង ប្រពៃណីពីបុរាណ បើ សិនជាមានការខកខានខុសលើសលស់ពាក្យពេចន៍ឆ្គាំឆ្គង មិនត្រូវតាមទំនុកទំនងស្រុកភូមិលោកមេបា សូមលោកមេបាមេត្តា បំពេញឱ្យទានខ្ញុំបាទ សូមប្រសាសន៍ សូមទានជ្រាប ។

**- មេបា** : ឥឡូវនេះ អ្នកទាំងបីសូមមកពាក់អាវផាយ យើងជាមេបាសូមបំពាក់ឋានន្តរស័ក្ដិជាមហាទេព, មហាមន្ត្រី, មហាវិជ្ជា សូមលោកទាំងបីបំរើកិច្ចទម្រង់ការឱ្យបានសេចក្ដីសុខចំរើនតទៅ ។

~**មេបា** : សូមទានជ្រាបជំរាបលោកមេបា កាលឃ្លាមុនខ្ញុំបាទសូមពាក់អាវផាយរំសាយមាត់ថង់ លោកក៏ព្រមអនុញ្ញាត ឥឡូវខ្ញុំបាទមកឃ្លានេះទៀត មានប្រដាប់សំរាប់ខ្លួន

កាលដើមនាងអ្នកផ្លូវស្រីទាំងបីនាក់មកសុំស្តីដណ្តឹងកូនស្រីលោក មេបា លោកមិនសម្រេចការថាខ្លួននាងជាស្រី ឥឡូវខ្ញុំបាទមកឃ្លានេះទៀតនៃ សូមក្រាបប្រណិប័តន៏ សុំស្តីនាង(........) ជាកូន លោក (...........)និងអ្នកស្រី (............)ផ្ទះនៅភូមិ...........ឃុំ.............ស្រុក.............ខេត្ត............ ។ សូមជាសាច់ ជា សន្ដាន ជាស្ពានមេត្រី សុំស្តីដណ្តឹងជាគូស្រកតរៀងទៅ សមដូចពាក្យអ្នកផ្លូវស្រីសំដីពីមុន សូមប្រសាសន៏ សូមទានជ្រាប ។

~**មេបា** : ឥឡូវនេះយើងជាមេបាបានឯកភាពគ្នាល្មមនឹងទុកដាក់កូនស្រីទៅឱ្យលោកចៅមហាហើយ ។

~**ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនចៅមហាខ្ញុំបាទមកសុំស្តីដណ្តឹងកូនលោកមេបាលោក ក៏ព្រមអនុញ្ញាត ឥឡូវខ្ញុំបាទមកឃ្លានេះទៀត សូមនាំអំណរគុណ មានចេកទុំនំផ្អែម ផល្លានុផល ដាក់តម្កល់លើល្វែងចន្ទ ផ្ទះ លោកមេបា សូមឱ្យលោកពិតពិលរមើលមើល បើខ្វះខាតកន្លែងត្រង់ណា សូមឱ្យលោកខន្តីអភ័យទោសស ឬលោកមេបាចង់ឱ្យ ចៅមហាខ្ញុំបាទរៀបរាប់ផ្លែឈើនោះ ចៅមហាខ្ញុំបាទនឹងចាត់អាជ្ញាកណ្តាល លោកអ្នកភ្លេង ដើម្បីរៀបរាប់ផ្លែឈើជូនលោក មេបា សូមប្រសាសន៏ សូមទានជ្រាប ។

~**មេបា** : យើងជាមេបា ខ្លួនកាន់តែចាស់ ភ្នែកក៏ងងឹត ត្រចៀកក៏ថ្លង់ មិនអាចមើលឃើញសព្វគ្រប់ផ្លែឈើទាំង៣៦ មុខនោះបានទេ សូមអញ្ជើញលោកអាជ្ញាកណ្តាលមកឡើងបេះប្រឡេះរាប់ផលានុផលទាំងអស់ ហើយជំរាបជូនមេបាអោយបានជ្រាប សូមអញ្ជើញ ។

~**ចៅមហា** : សូមអញ្ជើញលោកអ្នកភ្លេងឡើងរាប់ផ្លែឈើ ។

~**អ្នកភ្លេង** : (ភ្លេងច្រៀងចប់ និយាយ)

ពេលនេះក្រុមអ្នកភ្លេងយើងខ្ញុំបានរាប់ផ្លែឈើជូនលោកមេបារួចរាល់សព្វគ្រប់ អស់ហើយ ឃើញថាគ្រប់៣៦មុខហើយ សូមទានជ្រាប ។

~**មេបា** : តើអ្នកដែលបានឡើងបេះប្រឡេះនេះ តើអ្នកមានសូកនឹងអ្នកផ្លូវត្រូវនឹងអ្នកចៅមហាដែរឬទេ?

~**អ្នកភ្លេង** : ខ្ញុំបាទឥតមានសូកនឹងអ្នកផ្លូវត្រូវនឹងអ្នកចៅមហាទេ ខ្ញុំបាទសច្ចាយកត្រង់ថាឃើញ៣៦មុខពិតប្រាកដមែន ។

~**មេបា** : បើអ្នកឃើញថាគ្រប់៣៦មុខហើយ យើងជាមេបាប្រកាន់នូវធម៌សច្ចៈខន្តី មេត្តា ករុណា ឧបេក្ខា សន្ដោសប្រោសប្រណីដល់អ្នកទាំងពីរដែលទៅឡើងបេះប្រឡេះរាប់នេះ មេបាយើងសូមជូនមួយចំណែក តែសូមឱ្យអ្នកជួយប្រសិទ្ធិពរជ័យដល់កូនប្រុសកូនស្រីទាំងពីរ ព្រមទាំងលោកមេបាទាំងសងខាងផងចុះ ។

**(ភ្លេងជូនពរ)**

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនចៅមហាខ្ញុំបាទ បាននាំអំណរគុណមកជូនលោកមេបា ក៏បានទទួលសព្វគ្រប់ហើយ ឃ្លានេះខ្ញុំបាទគោរពសូមស្នើនឹងលោកមេបា តើទំនៀមទម្លាប់ស្រុក ភូមិលោកមេបា ស្លាដក់ ស្លា កន្សែង ស្លាកំណត់ ស្លាទាំងបីបទ តើលោកកំណត់ពិសាស្លាណាជាមុន ពិសានៅល្វែងណា ល្វែងតាកឆ្វេង ឬល្វែងចន្ទ លោក ពិសាមានភ្លេង ឬ ពិសាសម្ងាត់ ចៅមហាខ្ញុំបាទនឹងប្រតិបត្តិតាមទំនៀមទម្លាប់ស្រុក ភូមិ លោកមេបា សូមប្រសាសន៍ សូមទាន ជ្រាប ។

**-មេបា** : ទំនៀមទម្លាប់ច្បាប់សណ្ដាប់ធ្នាប់ស្រុកមេបាពិសាស្លាដក ស្លាកន្សែងជាមុន ពិសានៅទីល្វែងតាកឆ្វេង ពិសាមានភ្លេង ។

**-ចៅមហា** : សូមលោកថង់រងរៀបទឹកផ្ដិល សំពត់ផ្ទត់ដើម្បីរៀបចំពិសាស្លា ។ សូមលោកអ្នកភ្លេងលេងបទ (ប៉ុកពើក កងសោយ និង សំបូងសង្រួង) ។

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនចៅមហាខ្ញុំបាទ បានលើកស្លាដកស្លាកន្សែង មកជូនលោក មេបា លោកក៏បានពិសារួចសព្វគ្រប់ហើយ ឃ្លានេះខ្ញុំបាទសូមស្នើលោកមេបា តើទំនៀមទម្លាប់ស្រុក ភូមិលោកមេបាធ្លាប់ អង្គុយរង់ចាំទទួលពិសានៅល្វែងណា ល្វែងតាក ឆ្វេង ឬល្វែងច័ន្ទ ? សូមប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : ទំនៀមទម្លាប់ស្រុក ភូមិខ្ញុំធ្លាប់អង្គុយរង់ចាំនៅទីល្វែងចន្ទ ។

-ចៅមហា : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនខ្ញុំបាទបានគោរពអញ្ជើញលោកមេបាតាំងពីល្វែងតាកឆ្វេងរៀងទៅល្វែងជ័យ ល្វែងចន្ទឱ្យបានសព្វគ្រប់ ឃ្លានេះខ្ញុំបាទសូមគោរពទៅហែហមនាំពេលាវាសីចេកមាសកូនស្រីលោកមេបា និងពេលាវាសីចេកមាសកូនប្រុស ចៅមហាខ្ញុំបាទមកជំរាបជូនលោកមេបានោះវេលាម៉ោង............សូមប្រសាសន៍ សូមទានជ្រាប ។ (ភ្លេង............) (ពេលភ្លេងចប់ ចៅមហានិយាយ) លោកមេបាអញ្ជើញទៅអង្គុយនៅល្វែងចន្ទ ។

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនខ្ញុំបាទបានទៅហែហមនាំពេលាវាសីចេកមាសកូនប្រុស-ស្រី មកជំរាបលោកមេបា ឯកិច្ចការសព្វសារពើដូចម្ដេចម្ដា មានដូចតទៅ នៅក្នុងការកំណត់របស់លោកគ្រូអាចារ្យស្រាប់ ។

ចំណែកកិច្ចការបន្ត សូមលោកមេបាបង្គាប់រាប់ជាមកលើខ្ញុំបាទ និងសូមទទួលតាមច្បាប់រណ្ដាប់ការអស់លោកមេបាតរៀងទៅ ។ សូមប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : ខ្ញុំបាទបានទទួលពេលា តែខ្ញុំបាទអត់ផ្ទះរៀបវិវាហមង្គលការ សូមបង្គាប់ទៅអ្នកចៅមហាឱ្យសង់ផ្ទះរះសម្បែងតាកឆ្វេង៤ល្វែងឱ្យហើយក្នុងថ្ងៃហ្នឹង ។

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនលោកមេបាបានបង្គាប់រាប់ជាឱ្យចៅមហាខ្ញុំបាទសង់ ផ្ទះរះសម្បែងតាកឆ្វេង៤ល្វែង ហេតុដូចនេះ

ខ្ញុំបាទសូមលោកមេបាអនុញ្ញាត ត្បិតថ្ងៃក៏កៀក ខែក៏ជិត ខ្ញុំបាទគិតគូរសង់ផ្ទះរះ សម្លៀងមិនទាន់ ខ្ញុំបាទសូមប្រគល់ប្រាក់ចំនួន...................ជំនួសថ្លៃផ្ទះ ហើយសុំផ្ទះលោកមេបារៀបវិវាហមង្គលការ ។ សូម ប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : ចុះឥឡូវនេះ ប្រាក់ខាន់ស្លានៅឯណា ?

**-ចៅមហា** : តើលោកមេបាបានទទួលប្រាក់ខាន់ស្លាចំនួនប៉ុន្មានហើយ ពីថ្ងៃមុន ?

**-មេបា** : យើងបានទទួល ៣.០០០កហាបណៈហើយ

តើប្រាក់ទាំងបីពាន់កហាបណៈនេះលោកចាន់ទុកជាប្រាក់ខាន់ស្លា ឬសម្រាប់ហូបពិសាក្នុងកិច្ចទម្រង់ការ ។

**-ចៅមហា** : ប្រាក់ចំនួន ៣.០០០កហាបណៈនេះ ១.៥០០សម្រាប់ហូបពិសា និង ១.៥០០ទៀតសម្រាប់ទុកជាប្រាក់ ខាន់ស្លា ។

**-មេបា** : បានទទួលដឹងឮ.....................

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនចៅមហាខ្ញុំបាទបានប្រគល់ប្រាក់ជូនលោកមេបា លោកក៏ព្រមទទួល ឃ្លានេះចៅមហាខ្ញុំបាទ សុំចូលតាមច្រក សុំដករនុក សុំកំពង់ដងទឹក សុំដីសង់រោងខាន់ស្លា សុំទាំងដីធ្វើបង្ការ ចង្ក្រានចុងភៅ សុំទាំងផ្លូវបវរទេះ ចូលមកដាក់ក្នុងភូមិ សុំព្រៃកាប់អុស ព្រៃដោះទឹកសត្វតូច-ធំ ក្រែងស្រុក ភូមិលោកមេបា មានអារក្ស អ្នកតាឯណាពូកែ ។ សូមលោកបង្វែរឱ្យចៅមហាខ្ញុំបាទផង មហាខ្ញុំបាទសុំដីត្រង់ណាវាលចងគោ ក្រែងលោលោក មេបាមានដំណាំដាំដុះ ដូចជាចេក អំពៅ ត្រាវ ដំឡូង ស្វាយ ខ្នុរ ល្មុត សេដា ទៀប ម្ទូ ស្លា ត្របែក ដូង ក្រែងគោខ្ញុំបាទយិត យោងបេះបោច បាក់មែករហែកធាងមួយពីរ សូមលោកមេបាមេត្តាអនុញ្ញាតដល់ចៅមហាខ្ញុំបាទផង ។ សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : បានទទួលសំណូមពរ និង អនុញ្ញាតតាមការសុំ......

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនមហាខ្ញុំបាទ សុំដីសង់រោងខាន់ស្លា លោកក៏ព្រម អនុញ្ញាត ឥឡូវចៅមហាខ្ញុំបាទ ក្នុងឃ្លានេះទៀត សុំលើកជណ្តើរចាស់ ផ្លាស់ជណ្តើរថ្មី សុំបើកជញ្ជាំងចងភ្ជាក់ដៃ សូមលោក មេបាចាត់អាជ្ញាកណ្តាលឱ្យទៅអង្កេតពិនិត្យមើល ក្រែងមានជញ្ជៀនមាស ចិញ្ចៀនប្រាក់ ច្រឡំទុកដាក់ក្នុងថតរបាជញ្ជាំង តាំងពី ល្វែងតាកឆ្ពៀងរៀងល្វែងជ័យដល់ល្វែងច័ន្ទ សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : អនុញ្ញាតតាមសម្តី

**-ចៅមហា** : ខ្ញុំបាទស្នើលោកមេបាទុកឱ្យហើយ ក្រែងលោកមេបាមិនបានអង្គុយរង់ចាំនៅក្នុងកិច្ចមង្គលការនេះ ចៅ មហាខ្ញុំបាទសូមស្នើរៀបចំពិធីមួយចំនួនដូចជា : កាត់សក់ សូត្រមន្ត សែនក្រុងពាលី សែនចងដៃកូនប្រុស-ស្រី

រៀងផ្លែឈើ ជុំពេលា ជាវខាន់ស្លា ។ល។ លុះដល់ថ្ងៃស្អែក ជាថ្ងៃបរមសុខា ចៅមហាខ្ញុំបាទនឹងសុំនាំផ្កាស្លាជ័យ ម្លូជ័យ និង អ្នកសាមីខ្លួនមក ប្រគល់ជូនលោកមេបាជាកិច្ចបញ្ចប់ទម្រង់ការ ។ សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា** ៖ សូមកាត់ចុះ តែសុំឱ្យអែបទៀបខាងជាមួយគ្នា ។

**-ចៅមហា** ៖ ឥឡូវលោកមេបាបានអនុញ្ញាតឱ្យចៅមហាយើងខ្ញុំរៀបចំកាត់សក់បង្កក់សិរីដល់គូស្វាមី ដើម្បី........ (អត្ថន័យ + ពិធីកាត់សក់ + ភ្លេងសារិកាកែវ) ។ និយាយក្រោយពីកាត់សក់រួច ប្ញងសង្រួងរកកន្ទ្រៃមាស ក្រាសប្រាក់ ។ល។

## ( រៀបចំពិធីកាត់សក់ បង្កក់សិរី )

ទទួលភ្ញៀវកិត្តិយសពិសាភោជនាអាហារ (ពេលរសៀល)

**-ចៅមហា** ៖ និយាយពាក្យក្រុងពាលី (ម៉ោង៤) ពិធីក្រុងពាលី ។

**-មេបា** ៖ សូមលោកចៅមហារៀបចំកិច្ចសែនក្រុងពាលីនៅខាងត្បូងល្វែងចន្ទ ផ្ទះលោកមេបា

**-ចៅមហា** ៖ សូមលោកអ្នកភ្លេងលេងបទកងសោយ អញ្ជើញក្រុងពាលី ។

**(ភ្លេងលេង)**

**-ចៅមហា** ៖ (និយាយ) សុំរៀងផ្លែឈើ ឬ បុកលក្ខណ៍ មានភ្លេង៤បទ រកប្រុស៤ ស្រី៥ រួមមាន ៖

-ប្រុសឈ្មោះ ៖ ជ័យ , សួស , មាន , បាន

-ស្រីឈ្មោះ ៖ កែវ , កង , មាស , ប្រាក់ , ពិទូរ្យសូរ្យកាន្ត

**-ចៅមហា** ៖ (និយាយ) សូមទានជ្រាប ជំរាបអស់លោកមេបា ជុំពេលា និងជាវខាន់ស្លា លោកមេបាយកណាជាមុន ទុកណាជាក្រោយ សូមប្រសាសន៍ សូមទានជ្រាប ។

**-មេបា** ៖ ទំនៀមទម្លាប់ស្រុកមេបា យកជុំពេលាជាមុន ។

**-ចៅមហា** ៖ សូមទានជ្រាបជំរាបអស់លោកមេបា ពេលា សព្វសំរិទ្ធិរង្គ ពេញវង់ ជាន់ឆាយពេលណាមួយ សូមប្រ សាសន៍ សូមទានជ្រាប ។

**-មេបា** ៖ ពេលាមានអំពីលោកព្រះអាចារ្យ ។

**-ចៅមហា** ៖ សូមទានជ្រាបជំរាប់លោកមេបា....................ដល់កូនប្រុស-ស្រី ហេតុដូច្នេះសូមលោកបំពេញពេលា ជាសាធុ ។

**-មេបា** ៖ សាធុ ៣ដង

**-ចៅមហា** ៖ (**និយាយពីរជាវខាន់ស្លា**)

**-មេបា** ៖ សុំយកភាសាលោកអ្នកភ្លេង

**-ចៅមហា** : បើអញ្ចឹង សូមគោរពអញ្ជើញលោកអ្នកភ្លេងលេងបទជាវខាន់ស្លា (ជាចំរៀងចាប៉ីដងវែងក៏បាន ឬចំរៀងភ្លេងការក៏បាន) ដើម្បីជូនលោកមេបា ។

(ជ្រងដើមបទមុន.........ចាប៉ីចាប់ផ្ដើម)

ជ្រងអើយជ្រងនាយ ជ្រងអ្នកបន្ទាយ ជជាយឡើងគាល់ អស់លោកមេបា លោកអង្គុយរៀងរាល់ ជជាយឡើងគាល់ សុំជាវខាន់ស្លា ។

**ច្រៀងថ្ងៃ** (ចប់) អ្នកភ្លេងសួរលោកមេបា តើកូនបង កូនកណ្ដាល ឬកូនពៅ លោកកាន់តាមរាជស័ក្តិ , ឧត្តុង្គស័ក្តិ, បុរាណស័ក្តិ ឬ ភពស័ក្តិ ? លោកកាត់ប៉ុន្មានតម្លឹង ? ប៉ុន្មានស្លឹង ? ប៉ុន្មានបាត ?

**-មេបា** : កូនខ្ញុំបាទជាកូនច្បង ខ្ញុំសូមកាត់តាមបុរាណស័ក្តិ , កាត់១៩ដំឡឹង ៤ស្លឹង ២បាត ប្រាក់ត្រាប្រាសាទ តាគង់តាគាំដើមដៃ ។

**(សម្រាកពេលយប់)**

## លុះដល់ព្រឹកឡើងថ្ងៃបន្ទើយមង្គលការ

**-អាចារ្យ** : រៀបបង្វិលពពិល (ទៀនភ្លឺ) (រួចឱ្យអ្នកភ្លេងលេងបទនាគព័ន្ធ ផាត់ជាយ)

-ហួតដាវ , បើកទៀប , បាយខុន , អាចារ្យឱ្យពរ..........................

-ព្រះថោងតោងស្បៃ........................................................

-សាកន្ទេស ចងសំពោង........................................................

## ពរពេលព្រឹកជាពរបញ្ចប់មង្គលការ

អស់ឱតេជៈព្រះអាទិត្យរៀងរះពីបូពិទិសា សូមឱ្យអ្នក និងនាងជាគូភរិយាបានមូលមិត្តសុខជាឧត្តម **នមោសេដ្ឋោ នមស្ការោ** ក្រួញក្រាបបង្គំដល់ព្រះចមភព ជាម្លប់ឧត្តមព្រះអង្គជាធំលើសភពផែនដី ។

-អស់ឱតេជះខ្ញុំក្រាបសំពះទន់ទាំងសិរសី សុំពរអំពីសម្ដេចព្រះជិនស្រី ឱ្យអ្នកការថ្មីជាប្ដីប្រពន្ធ សូមឈ្នះចង្រៃ ប្រាសចាកទុក្ខភ័យ ប្រសើរលើសលន់ ។ ឱព្រះគុណថ្លៃមានគុណលើសជន សូមព្រះគុណធ្ងន់មេត្តាឱ្យពរ ពឹងគុណព្រះធម៌ ប្រសើរបវរឈ្នះបាបខ្មាខ្មៅ ជំងឺដង្កាត់កុំបីរីររៃ ព្រះធម៌សាទរ ឱ្យពរឈ្នះភ័យ ។ ពឹងគុណព្រះសង្ឃ ធ្វើចិត្តឱ្យត្រង់ ប្រតិបត្តិថ្លាថ្លៃ សង្ឃជាស្រែបុណ្យ ជនដឹងសព្វថ្ងៃ ព្រះសង្ឃឱ្យជ័យ ឱ្យពរឈ្នះរោគ ។ គុណកែវទាំងបី សូមឈ្នះចង្រៃ ប្រាសចាកទុក្ខសោក សុខក្នុងលោកិយ សុខដល់បរមលោក ចូលអ្នកទាំងពីរចាំយក ជឿជាក់ដាក់ក្នុងប្រាណ ចៅមហាខ្ញុំបាទឱ្យពរ ចូលអ្នកមានទ្រព្យគ្រប់ប្រការ មានគោក្របី គុ ទូ កៅអី ម៉ូតូហុងដា សឹងមានជាទ្រព្យ ឧត្តមចូលមកជួបជុំចតទុកពេញត្រៀបត្រា ។

-នាងប្រតិបត្តិប្ដី ប្រៀបដូចជាស្រីបវរកញ្ញា បំរើព្រះឥន្ទជាស្ដេចទេវតា នៅត្រើយត្រឹង្សា ពិភពសួគ៌នាយ ។ នាងស្រឡាញ់ប្ដីធ្វើចិត្តឱ្យស្លូត កុំបីភរភូត ចិត្តកុំវាយមាយ នាងប្រតិបត្តិប្ដី ដូចបាវនិងនាយ ។

ឱនលំទោនកាយថ្វាយវរវន្ទា នាងស្រឡាញ់ប្តីរៀងមួស្លាបារី សព្វគ្រប់វេលា បើនាងចូលដេកខាងឆ្វេងប្តីជា ឱ្យនាងមានអាយុវយឺនយូរតទៅ នាងអើយមាត្រា ច្បាប់ស្រីនេះណា ក្រណាស់ណាពៅ នាងប្រឹងឱ្យបាន ជាស្ពានដើរទៅ កាន់នាលំនៅពិភពសួគ៌នាយ ។ កបកើតទ្រព្យបរិបូណ៌ហូរហៀវ ពោរពាសស្តុកស្តម្ភ ចូលអ្នកចងចាំទុក ពរនេះទៅមុខឈ្នះទុក្ខរោគា ពរនេះមាំ មួនប្រាំពីប្រការ ព្រះប្រោសទេសនាថាប្រសើរក្រៃ **អាយុវឌ្ឍនោច** ចំរើនពរពាក្យពិតនិយាយ

សូមឱ្យអ្នកទាំងពីរមានអាយុ ១០០ឆ្នាំម្នាក់ បានដូចទំនាយទុក្ខទោសរសាយ រលត់គ្មានសល់ ។

**ពលវឌ្ឍនំ** សូមឱ្យអ្នកទាំងពីរ មានកំលាំងប្រណាំងស្មើខ្យល់ ។

**ធនវឌ្ឍនោ** ពរនេះថ្កើងថ្កានរកស៊ីកើតផល កើតភាគសម្បត្តិ ។

**វណ្ណវឌ្ឍនោ** សូមឱ្យមានសប្បុរសប្រផូរផង់ផាត់ ។

**សុខវឌ្ឍនោ** សុខលែងឈឺថ្កាត់ រកទ្រព្យសម្បត្តិសំបូរធូរចាយ ។

**យសស័ក្តិវឌ្ឍនោ** បរិវារមូលមក មូលមិត្តជិតឆ្ងាយ ។

**សិរីវឌ្ឍនោ** សិរីរាង្គកាយ មាសប្រាស់ទាំងឡាយសំបូរហូរចូល ។

មានទ្រព្យមិនខ្វះទាំងថ្មីទាំងចាស់ដូចគេប្រមូលមានស្រូវជង្រុក កើបទុកឱ្យមូល ផាមួងព្រៃហូល ស្បៀកពាក់មិនអស់ ។ ម្យ៉ាងទៀតលែងក្រ មានទ្រព្យបវរ ចិត្តល្អរហូត ចិត្តស្លូតត្រង់ស្មោះ ទ្រព្យចាយមិនអស់ ចែកទៅជាទាន ជាទុនតទុក តទៅមុខទុកជាប្រធាន ឱ្យដឹងគុណកិច្ច កុំភ្លេចវិញ្ញាណរកស៊ីឆាប់មានរាល់ថ្ងៃតទៅ ។

ចូរអ្នកទាំងពីរដឹងគុណពីថ្ងៃនេះតទៅ ពិតជាបានសុខជ័យហោង ! សួសហោង.................................................. សុខហោង សុខដូចមាត់ប្រាកដដូចពាក្យថា មែនហោង (មែន) បើមែនមានអ្វីជបន្ទាល់..................(ហ៊ោ) ។

**(ចប់)**

**១~**ច្បាប់គោរពមាតាបិតា (**បណ្ឌិតអ៊ូចុង**) **២~**កិរិយាចិញ្ចឹមជីវិតដោយកំរ (**បណ្ឌិតអ៊ូចុង**)

**៣~**ច្បាប់ប្រដៅជនប្រុសស្រី (**ភទីគ្រូមង្ស៊ុយ**)**៤~**កេរ្តិ៍កាលថ្មី (**ភទីគ្រូមង្ស៊ុយ**)

**៥~**ច្បាប់ល្បើកថ្មី (**ភទីគ្រូមង្ស៊ុយ**)

**ថតសំលេងដោយលោកគ្រូអាចារ្យ យុត ឃឹម ជាកាសែតម៉ាញេ**

**និង MP3** ( 1CD MP3 ) **=**

**Please contact Sales@AngkorLink.com**